# ពិធីការសម្រាប់ទីកន្លែងគោរពបូជា៖ ឧបសម្ព័ន្ធ F

**បច្ចុប្បន្នភាពថ្មីៗ៖**
7/1/20៖ សូមកត់សម្គាល់ថាការណែនាំឧស្សាហកម្មករណីជំងឺ COVID-19 នៃរដ្ឋ California សម្រាប់ទីកន្លែងគោរពបូជា និងអ្នកផ្តល់សេវាកម្មសាសនា និងពិធីបុណ្យប្បធម៌ត្រូវបានធ្វើបច្ចុប្បន្នភាព។ ចុច ទីនេះ ដើម្បីពិនិត្យមើលវា។
7/9/20៖ បានផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងអត្ថប្រយោជន៍នៃការឈប់សម្រាករបស់បុគ្គលិក និងការកែលម្អប្រព័ន្ធខ្យល់ចេញចូល
7/16/2020៖ បានធ្វើបច្ចុប្បន្នភាពដើម្បីអនុលោមតាមសេចក្តីបង្គាប់ចុះថ្ងៃទី 13 ខែកក្កដាឆ្នាំ 2020 ដែលបានចេញដោយសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលសាធារណៈនៃរដ្ឋ ដែលតម្រូវឲ្យបិទប្រតិបត្តិការក្នុងអគារទាំងអស់របស់ទីកន្លែងគោរពបូជា។ ប្រតិបត្តិការក្នុងអគារនៅទីកន្លែងគោរពបូជាត្រូវបានបិទសម្រាប់សាធារណជន។ សកម្មភាពសាធារណៈ ដូចជាសេវាកម្ម ពិធីអាពាហ៍ពិពាហ៍ និងពិធីបុណ្យសព អាចបន្តធ្វើនៅខាងក្រៅអគារនៅលើទីធ្លានៃទីកន្លែងគោរពបូជា ដោយអនុលោមតាមពិធីការដែលបានកែសម្រួលនេះ ឬតាមបែបនិម្មិត ដោយប្រើទីកន្លែងនេះ ឬទីកន្លែងផ្សេងទៀតជាចំណុចរៀបចំពិធី។
7/17/20៖ បានផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងរបាំងមុខ និងការពិនិត្យរោគសញ្ញាបុគ្គលិក និងភ្ញៀវ។

នាយកដ្ឋានសុខភាពសាធារណៈរបស់ខោនធី Los Angeles កំពុងអនុវត្តវិធីសាស្រ្តតាមដំណាក់កាល ដែលបានគាំទ្រដោយវិទ្យាសាស្រ្ត និងជំនាញការសុខភាពសាធារណៈ ដើម្បីអនុញ្ញាតឲ្យទីកន្លែងគោរពបូជាបើកទ្វារឡើងវិញដោយសុវត្ថិភាព។ ដោយអនុលោមតាមការណែនាំឧស្សាហកម្មករណីជំងឺ COVID-19 នៃរដ្ឋ California សម្រាប់ទីកន្លែងគោរពបូជា និងអ្នកផ្តល់សេវាសាសនា និងពិធីបុណ្យប្បធម៌ចុះថ្ងៃទី 1 ខែកក្កដាឆ្នាំ 2020 និងសេចក្តីបង្គាប់ចុះថ្ងៃទី 13 ខែកក្កដាឆ្នាំ 2020 ដែលបានចេញដោយមន្ត្រីសុខាភិបាលសាធារណៈរបស់រដ្ឋជាការឆ្លើយតបនឹងការរាតត្បាតនៃ ជំងឺ COVID-19 កាន់តែច្រើននៅទូទាំងរដ្ឋ ពិធីការនេះផ្តល់ការណែនាំសម្រាប់ឲ្យទីកន្លែងគោរពបូជា និងអ្នកផ្តល់សេវាសាសនា និងពិធីបុណ្យប្បធម៌ (ត្រូវបានសំដៅជារួមថា "ទីកន្លែងគោរពបូជា") ផ្តល់បរិយាកាសដែលមានសុវត្ថិភាពនិងស្អាតដល់បុគ្គលិក អ្នកហាត់ការនិងអ្នកទទួលការបណ្តុះបណ្តាល អ្នកស្ម័គ្រចិត្ត បញ្ញវន្ត និងបុគ្គលិកប្រភេទផ្សេងៗទៀតទាំងអស់ (ត្រូវបានសំដៅជារួមថា "បុគ្គលិក") ក៏ដូចជាសមាជិកចូលរួម អ្នកគោរពបូជា ភ្ញៀវ ។ល។ (ត្រូវបានសំដៅជារួមថា "ភ្ញៀវ" ឬ "សមាជិកចូលរួម")។ បន្ថែមលើល័ក្ខខ័ណ្ឌទៅលើទីកន្លែងគោរពបូជាដែលបានដាក់ចុះដោយមន្ត្រីសុខាភិបាលសាធារណៈរបស់រដ្ឋ ទីកន្លែងគោរពបូជាក៏ត្រូវតែគោរពតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងពិធីការសម្រាប់ទីកន្លែងគោរពបូជានេះផងដែរ។

សូមកត់សម្គាល់៖ ពិធីការនេះមិនតម្រូវឲ្យទីកន្លែងគោរពបូជាបន្តសកម្មភាពណាមួយដោយផ្ទាល់ឡើយ។ លើសពីនេះ វាត្រូវបានណែនាំយ៉ាងមុតមាំឲ្យទីកន្លែងគោរពបូជាបន្តសម្របសម្រួលសេវាកម្មពីចម្ងាយ និងសកម្មភាពពាក់ព័ន្ធផ្សេងៗទៀតសម្រាប់ជនដែលងាយរងគ្រោះនឹងជំងឺ COVID-19 រួមទាំងជនចាស់ជរា និងជនដែលមានជំងឺច្រើនក្នុងពេលតែមួយ។

ពិធីការនេះមិនមែនសម្រាប់ការរៀបចំ និងសេវាកម្មម្ហូបអាហារ ការដឹកជញ្ជូនទំនិញទៅអ្នកទទួលសេវាកម្មថែទាំកុមារនិងការថែទាំនៅពេលថ្ងៃ សាលារៀននិងសកម្មភាពអប់រំ ការផ្តល់ការថែទាំតាមផ្ទះ ការប្រឹក្សាយោបល់ ការងារការិយាល័យ និងសកម្មភាពផ្សេងៗទៀតដែលទីកន្លែង និងស្ថាប័នគោរពបូជាអាចនឹងផ្តល់ជូនឡើយ។

ពិធីការនេះអាចនឹងត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលមានព័ត៌មាន និងធនធានបន្ថែម ដូច្នេះសូមប្រាកដថាពិនិត្យមើលគេហទំព័រ LA County http://www.ph.lacounty.gov/media/Coronavirus/ ជាប្រចាំសម្រាប់បច្ចុប្បន្នភាពផ្សេងៗទៅលើឯកសារនេះ។ ចូរកត់សម្គាល់ផងដែរថា នាយកដ្ឋានសុខភាពសាធារណៈរបស់រដ្ឋ California នឹងធ្វើការពិនិត្យឡើងវិញដើម្បីវាយតម្លៃផលប៉ះពាល់នៃសេចក្តីបង្គាប់របស់រដ្ឋ និងពិធីការទាំងនេះរយៈពេល 21 ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃសេចក្តីបង្គាប់មន្ត្រីសុខាភិបាលសាធារណៈរបស់រដ្ឋ។

បញ្ជីត្រួតពិនិត្យនេះគ្របដណ្តប់៖
(1) គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពបុគ្គលិក
(2) វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ
(3) វិធានការណ៍ដើម្បីធានាបាននូវការគ្រប់គ្រងការឆ្លងជំងឺ
(4) ការទំនាក់ទំនងជាមួយបុគ្គលិក ភ្ញៀវ និងសមាជិកចូលរួម
(5) វិធានការណ៍ដើម្បីធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព។

ចំណុចសំខាន់ៗទាំងប្រាំនេះ ត្រូវតែបានដោះស្រាយ ស្របពេលដែលទីកន្លែងរបស់អ្នកអនុវត្តពិធីការសម្រាប់ទីកន្លែងគោរពបូជារបស់ខ្លួន។

**ស្ថាប័នទាំងអស់ដែលត្រូវបានគ្របដណ្តប់ដោយការណែនាំនេះ ត្រូវតែដាក់ចុះនូវវិធានការណ៍ដែលអាចអនុវត្តបានទាំងអស់ ដែលមានរាយនៅខាងក្រោម និងត្រូវត្រៀមខ្លួនដើម្បីពន្យល់ពីមូលហេតុនៃវិធានការណ៍ណាមួយដែលមិនត្រូវបានអនុវត្ត គឺមិនអាចអនុវត្តបានសម្រាប់ទីកន្លែង។**

| | |
|---|---|
| **ឈ្មោះទីកន្លែងគោរពបូជា៖** | |
| **អាសយដ្ឋានទីកន្លែង៖** | |
| **ចំនួនមនុស្សអតិបរមា តាមច្បាប់អគ្គីភ័យ៖** | |
| **ប្រហាក់ប្រហែលទំហំទីធ្លាគិតសរុបជាហ្វីតការ៉េ ដែលប្រើដោយភ្ញៀវ និងសមាជិកចូលរួមសម្រាប់សេវាកម្ម៖** | |

នៅក្នុងពិធីការនេះដែលមានដូចតទៅនេះ ពាក្យ "បុគ្គលិក" មានន័យថារាប់បញ្ចូលទាំងបុគ្គលិក អ្នកស្ម័គ្រចិត្ត បុគ្គលិកហាត់ការនិងសិក្ខាកាម បញ្ញវន្តនិងបុគ្គលផ្សេងៗទៀតដែលបំពេញការងារនៅទីកន្លែងនេះ។ ពាក្យ "ភ្ញៀវ" គួរត្រូវបានយល់ថារាប់បញ្ចូលសមាជិកនៃការប្រមូលផ្តុំ អ្នកគោរពបូជា និងសាធារណជនដែលមកកាន់ទីកន្លែងក្នុងនាមជាភ្ញៀវ។ ពាក្យ "ទីកន្លែង" និង "ផ្ទះគោរពបូជា" ទាំងពីរនេះសំដៅលើអគារដែលធ្វើការគោរពបូជា និងអគារឬទីធ្លាជាប់គ្នាដែលបានអនុញ្ញាតឲ្យធ្វើសកម្មភាពប្រមូលផ្តុំ។

## A. គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពនិយោជិត (បុគ្គលិក) (គូសធីកទាំងអស់ដែលអនុវត្តសម្រាប់ទីកន្លែង)

- ❑ បុគ្គលិកដែលអាចបំពេញកិច្ចការរបស់ខ្លួនពីផ្ទះ ត្រូវបានណែនាំឲ្យធ្វើដូច្នោះ។
- ❑ បុគ្គលិកងាយរងគ្រោះ (អ្នកដែលមានអាយុលើ 65 ឆ្នាំ អ្នកដែលមានបញ្ហាសុខភាពរ៉ាំរ៉ៃ) ត្រូវបានកំណត់ឲ្យធ្វើការងារដែលអាចធ្វើបានពីផ្ទះនៅគ្រប់ពេលដែលអាចធ្វើទៅបាន។
- ❑ បុគ្គលិកទាំងអស់ត្រូវបានប្រាប់ថាមិនឲ្យធ្វើការ បើសិនជាឈឺ និងត្រូវអនុវត្តតាមការណែនាំរបស់ DPH សម្រាប់ការដាក់ខ្លួនឯងឲ្យនៅដាច់ដោយឡែក បើសិនជាអាចធ្វើបាន។
- ❑ ព័ត៌មានអំពីអត្ថប្រយោជន៍នៃការឈប់សម្រាកដែលឧបត្ថម្ភដោយនិយោជក ឬរដ្ឋាភិបាលដែលបុគ្គលិកអាចនឹងមានសិទ្ធិទទួល ដែលនឹងធ្វើឲ្យវាកាន់តែមានភាពងាយស្រួលផ្នែកហិរញ្ញវត្ថុក្នុងការស្ថិតនៅផ្ទះ។ មើលព័ត៌មានបន្ថែមស្តីពី កម្មវិធីរដ្ឋាភិបាលដែលគាំទ្រការឈប់សម្រាកឈឺ និងសំណងបុគ្គលិកសម្រាប់ជំងឺ COVID-19 ដោយរាប់បញ្ចូលទាំងសិទ្ធិឈប់សម្រាកឈឺរបស់បុគ្គលិកក្រោម ច្បាប់ស្តីពីការឆ្លើយតបនឹងមេរោគកូរ៉ូណាដោយយកគ្រួសារជាអាទិភាព (Families First Coronavirus Response Act) និងសិទ្ធិរបស់បុគ្គលិកដើម្បីទទួលអត្ថប្រយោជន៍សំណងបុគ្គលិក និងការសន្និដ្ឋាននៃភាពទាក់ទងនឹងការងាររបស់ជំងឺ COVID-19 ពាក់ព័ន្ធនឹង បទបញ្ជាប្រតិបត្តិលេខ N-62-20 របស់អភិបាលរដ្ឋ
- ❑ **ដំណើរការការងារត្រូវបានកែទម្រង់ឡើងវិញទៅតាមកម្រិតដែលអាចធ្វើបាន ដើម្បីបង្កើនឱកាសសម្រាប់ឲ្យបុគ្គលិកធ្វើការងារពីផ្ទះ។**
- ❑ បន្ទាប់ពីទទួលព័ត៌មានថាមានបុគ្គលិក/អ្នកអនុវត្ត អ្នកម៉ៅការឯកជន និងបុគ្គលិកបណ្តោះអាសន្នម្នាក់ឬច្រើននាក់ធ្វើតេស្តវិជ្ជមាន ឬមានរោគសញ្ញាដែលដូចគ្នាជាមួយជំងឺ COVID-19 (ករណី) និយោជកមានគម្រោងដើម្បីឲ្យករណីទាំងនោះដាក់ខ្លួនឲ្យនៅដាច់ដោយឡែកនៅផ្ទះ និងតម្រូវឲ្យមានការនៅដាច់ពីគេដោយខ្លួនឯងភ្លាមៗសម្រាប់បុគ្គលិកដែលមានការប៉ះពាល់ជាមួយករណីនៅកន្លែងធ្វើការ។ គម្រោងរបស់និយោជកគួរតែពិចារណាពីពិធីការសម្រាប់បុគ្គលិកដែលបាននៅដាច់ពីគេទាំងអស់ ដើម្បីអាចទទួលបានឬធ្វើតេស្តរកជំងឺ COVID-19 ដើម្បីកំណត់ថាតើមានការប៉ះពាល់នៅកន្លែងធ្វើការបន្ថែមទៀតឬអត់ ដែលអាចតម្រូវឲ្យមានវិធានការណ៍គ្រប់គ្រងជំងឺ COVID-19 បន្ថែម។ មើលការណែនាំសុខភាពសាធារណៈនៅលើ ការឆ្លើយតបនឹងជំងឺ COVID-19 នៅកន្លែងធ្វើការ។
- ❑ ការត្រួតពិនិត្យបុគ្គលិកត្រូវបានធ្វើឡើងមុនពេលបុគ្គលិកអាចនឹងចូលមកកាន់កន្លែងធ្វើការ។ ការត្រួតពិនិត្យ ត្រូវតែរាប់បញ្ចូលការពិនិត្យទាក់ទងនឹងការក្អក ដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងអការ គ្រុនក្តៅឬគ្រុនរងា និងថាតើបុគ្គលិកបានប៉ះពាល់ជាមួយបុគ្គលដែលត្រូវបានគេដឹងថាបានឆ្លងជំងឺ COVID-19 ក្នុងរ

យៈពេល 14 ថ្ងៃចុងក្រោយឬក៏អត់។ ការត្រួតពិនិត្យទាំងនេះអាចធ្វើបានពីចម្ងាយ ឬដោយផ្ទាល់នៅពេលបុគ្គលិកមកដល់។ ការពិនិត្យសីតុណ្ហភាពក៏គួរតែធ្វើឡើងនៅកន្លែងធ្វើការផងដែរ បើសិនជាអាចធ្វើបាន។

- ❑ នៅក្នុងករណីដែលរកឃើញមាន 3 ករណីឬច្រើនជាងនេះនៅកន្លែងធ្វើការ (ដែលរួមមានករណីក្នុងចំណោមបុគ្គលិក និង/ឬសមាជិកការប្រមូលផ្តុំ)ក្នុងរយៈពេល 14 ថ្ងៃ នោះនិយោជកគួររាយការណ៍ពីក្រុមនេះទៅនាយកដ្ឋានសុខភាពសាធារណៈតាមរយៈលេខ (888) 397-3993 ឬ (213) 240-7821។ បើសិនជាចង្កោមត្រូវបានរកឃើញនៅកន្លែងធ្វើការ នាយកដ្ឋានសុខភាពសាធារណៈ នឹងចាប់ផ្តើមការឆ្លើយតបចំពោះការឆ្លងជាក្រុម ដែលរួមមានដូចជាការផ្តល់ការណែនាំ និងអនុសាសន៍អំពីការគ្រប់គ្រងការឆ្លងជំងឺ ការគាំទ្របច្ចេកទេស និងវិធានការណ៍គ្រប់គ្រងដែលជាក់លាក់សម្រាប់ទីកន្លែង។ អ្នកគ្រប់គ្រងករណីសុខភាពសាធារណៈ នឹងត្រូវបានចាត់តាំងដើម្បីធ្វើការស៊ើបអង្កេតការឆ្លងជាក្រុមដើម្បីដឹកនាំការឆ្លើយតបនៅទីកន្លែង។
- ❑ បុគ្គលិកដែលមានការប៉ះពាល់ជាមួយអ្នកដទៃទទួលបានរបាំងមុខសមស្របដែលគ្របច្រមុះ និងមាត់ដោយឥតគិតថ្លៃ។ បុគ្គលិកត្រូវពាក់របាំងមុខនេះគ្រប់ពេលវេលាក្នុងអំឡុងថ្ងៃធ្វើការ នៅពេលប៉ះពាល់ ឬទំនងជាប៉ះពាល់ជាមួយអ្នកដទៃ។ បុគ្គលិកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួនថាពួកគេមិនគួរពាក់របាំងមុខ គួរពាក់សន្ទះបាំងមុខដែលមានក្រណាត់រុំពីគែមខាងក្រោម ដើម្បីអនុលោមតាមបទបញ្ជារបស់រដ្ឋ ដរាបណាស្ថានភាពសុខភាពរបស់ពួកគេអនុញ្ញាតឲ្យធ្វើដូច្នេះ។ ក្រណាត់រុំដែលមានទម្រង់រឹតតឹងខាងក្រោមចង្កាគឺជាការល្អ។ មិនគួរប្រើម៉ាស់ដែលមានវ៉ាល់មួយផ្លូវឡើយ។ បុគ្គលិកមិនចាំបាច់ពាក់ក្រណាត់បាំងមុខពេលនៅម្នាក់ឯងនៅក្នុងការិយាល័យឯកជន ឬបន្ទប់តូចដែលមានរបាំងរឹងការពារខ្ពស់ជាងកម្ពស់បុគ្គលិកនៅពេលឈរនោះទេ។
- ❑ បុគ្គលិកត្រូវបានណែនាំឲ្យបោកគក់ ឬប្តូររបាំងមុខរបស់ខ្លួនជារៀងរាល់ថ្ងៃ។
- ❑ ឧបករណ៍ការពារផ្ទាល់ខ្លួនសមស្របត្រូវបានផ្តល់ឲ្យបុគ្គលិកតាមការចាំបាច់ ដោយរាប់បញ្ចូលដូចជាឧបករណ៍ការពារភ្នែក និងស្រោមដៃ ដែលទទួលខុសត្រូវលើការបោកគក់សំលៀកបំពាក់ និងក្រណាត់សាសនា ក្រណាត់គ្របកន្លែងអង្គុយឬកម្រាលឥដ្ឋ ឬក្រណាត់ផ្សេងទៀតដែលបានប្រើនៅក្នុងសេវាកម្ម ឬពិធីបុណ្យ។
- ❑ បុគ្គលិកត្រូវបានណែនាំឲ្យបោកគក់ក្រណាត់បាំងមុខរបស់ខ្លួនជារៀងរាល់ថ្ងៃ។
- ❑ ទីកន្លែងការងារទាំងអស់ត្រូវបានដាក់ឲ្យឃ្លាតពីគ្នាយ៉ាងតិច 6 ហ្វីតឬដោយការបាំង។
- ❑ ទីកន្លែងទូទៅ ដែលរួមមានបន្ទប់ទឹក និងទីកន្លែងដែលត្រូវបានប្រើដោយបុគ្គលិកប៉ុណ្ណោះ ត្រូវបានសម្លាប់មេរោគជាញឹកញាប់ទៅតាមកាលវិភាគដូចខាងក្រោម៖
  - ❑ កន្លែងចូល/កន្លែងរង់ចាំ ________________________________
  - ❑ ផ្លូវដើរក្នុងអគារ ________________________________
  - ❑ បន្ទប់ប្រជុំ ________________________________
  - ❑ កន្លែងធ្វើការរួមគ្នា ________________________________
  - ❑ បន្ទប់សម្រាក ________________________________
  - ❑ ជណ្តើរខាងក្រៅ /ជណ្តើរខាងក្នុង ________________________________
  - ❑ ជណ្តើរយន្ត ________________________________
  - ❑ បន្ទប់ទឹក ________________________________
  - ❑ ផ្សេងទៀត ________________________________
- ❑ បុគ្គលិកត្រូវបានហាមឃាត់មិនឲ្យបរិភោគ ឬផឹកនៅកន្លែងណាមួយនៅក្នុងទីកន្លែងក្រៅពីតំបន់បរិភោគអាហារដែលបានកំណត់ឡើយ ដើម្បីធានាថាម៉ាស់អាចត្រូវបានពាក់គ្រប់ពេលវេលា និងត្រឹមត្រូវ។
- ❑ សារធាតុសម្លាប់មេរោគ និងការផ្គត់ផ្គង់ដែលពាក់ព័ន្ធគឺមានសម្រាប់បុគ្គលិកនៅទីតាំងដូចខាងក្រោម៖

  ________________________________________________

- ❑ ទឹកអនាម័យលាងដៃដែលមានប្រសិទ្ធភាពប្រឆាំងជំងឺ COVID-19 គឺមានសម្រាប់បុគ្គលិកទាំងអស់នៅទីតាំងដូចខាងក្រោម៖

  ________________________________________________

- ❑ បុគ្គលិកត្រូវបានអនុញ្ញាតឲ្យសម្រាកឲ្យបានញឹកញាប់ដើម្បីលាងដៃរបស់ខ្លួន។
- ❑ បុគ្គលិកត្រូវបានណែនាំមិនឲ្យធ្វើការសួរសុខទុក្ខនៅផ្ទះ ឬការទស្សនកិច្ចក្រៅទីកន្លែងផ្សេងទៀតទៅកាន់នរណាម្នាក់ដែលបានធ្វើតេស្តវិជ្ជមានសម្រាប់ ឬចេញរោគសញ្ញាជំងឺ COVID-19 ឡើយ លុះត្រាតែជន នោះ

បានបំពេញរយៈពេលដាក់ខ្លួនឯងឲ្យនៅដាច់ដោយឡែក ឬនៅដាច់ពីគេដោយខ្លួនឯងដែលបានកំណត់។
- ❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានចែកចាយទៅបុគ្គលិកនីមួយៗ។
- ❑ បុគ្គលិកនីមួយៗ ត្រូវបានកំណត់ឧបករណ៍ផ្ទាល់ខ្លួន បរិក្ខារ និងលំហធ្វើការដែលបានកំណត់។ ការប្រើប្រាស់រួមគ្នានូវវត្ថុដែលបានប៉ះរួច ត្រូវបានកាត់បន្ថយ ឬលុបបំបាត់។
- ❑ គោលការណ៍ទាំងអស់ដែលបានពិពណ៌នានៅក្នុងបញ្ជីត្រួតពិនិត្យនេះក្រៅពីគោលការណ៍ដែលទាក់ទងនឹងល័ក្ខខ័ណ្ឌការងារ ត្រូវបានអនុវត្តទៅលើបុគ្គលិកដឹកជញ្ជូន និងក្រុមហ៊ុនផ្សេងៗទៀតដែលអាចស្ថិតនៅទីតាំងនោះក្នុងនាមជាភាគីទីបី។
- ❑ ស្រេចចិត្ត—ពិពណ៌នាពីវិធានការណ៍ផ្សេងទៀតៈ

_______________________________________________

## B. វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ

- ❑ សេវាកម្មសាសនា និងពិធីបុណ្យប្រឲ្យធម៌ខាងក្នុងអគារនៅតាមទីកន្លែងគោរពបូជាត្រូវបានហាមឃាត់រហូតដល់មានការជូនដំណឹងជាថ្មីដោយមន្ត្រីសុខាភិបាលសាធារណៈរបស់រដ្ឋ។ ជម្រើសផ្សេងអាចត្រូវបានប្រើសម្រាប់សេវាសាសនា និងព្រឹត្តិការណ៍ប្រឲ្យធម៌សាធារណៈ។ ជម្រើសទាំងនេះមានដូចជាៈ
  - ❑ សេវាកម្ម និងព្រឹត្តិការណ៍ត្រូវបានធ្វើឡើងនៅខាងក្រៅអគារដោយគោរពតាមសេចក្តីតម្រូវនៃការគ្រប់គ្រងការឆ្លងជំងឺ និងការរក្សាគំលាតរាងកាយ
  - ❑ សេវាកម្ម និងព្រឹត្តិការណ៍ត្រូវបានធ្វើឡើងតាមបែបនិម្មិតតាមរយៈការស្ទ្រីមផ្ទាល់ ឬការថតទុកសម្រាប់ផ្សព្វផ្សាយនៅពេលក្រោយ។
    - ▪ <u>ចូរកត់សម្គាល់ថាទីធ្លាក្នុងអគារនៅតាមទីកន្លែងគោរពបូជាអាចត្រូវបានប្រើជាទីកន្លែងសម្រាប់សេវាកម្ម និងព្រឹត្តិការណ៍ដែលធ្វើឡើងតាមបែបនិម្មិត ដរាបណាសេចក្តីតម្រូវនៃការគ្រប់គ្រងការឆ្លងជំងឺ និងការរក្សាគំលាតរាងកាយ ត្រូវបានអនុវត្តតាម ហើយមិនមានមនុស្សលើសពី 10 នាក់ចូលរួមនៅក្នុងដំណើរការផលិត និងផ្សព្វផ្សាយ។</u>
  - ❑ ពុំនោះទេការប្រើប្រាស់ទីធ្លាក្នុងអគារនៅទីកន្លែងត្រូវបានដាក់កម្រិតត្រឹមបុគ្គលិកដែលធ្វើសកម្មភាពមិនសាធារណៈ ឬនិម្មិត។
- ❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីលើកកម្ពស់ការរក្សាគំលាតរាងកាយនៅតាមព្រឹត្តិការណ៍ខាងក្រៅអគារ។
  - ❑ វិធានការណ៍ត្រូវបានអនុវត្ត (ការចុះឈ្មោះជាមុន ការរាប់ចំនួនអ្នកចូលរួមនៅច្រកចូល) ដើម្បីធានាថាចំនួនអ្នកចូលរួមមិនលើសពីចំនួនមនុស្សដែលអាចរក្សាគំលាតរាងកាយនៅក្នុងព្រឹត្តិការណ៍ខាងក្រៅអគារ។
  - ❑ ចំណតយានយន្តត្រូវបានរៀបចំឡើងវិញដើម្បីដាក់កម្រិតលើចំណុចប្រមូលផ្តុំ និងធានាបាននូវគំលាតសមស្រប (ឧទាហរណ៍ ដោយបិទកន្លែងចតចន្លោះៗនោះ)។
  - ❑ បើសិនជាសេវាកម្មបើកចូលខាងក្រៅអគារ ត្រូវបានផ្តល់ជូន រថយន្តត្រូវបានណែនាំឲ្យចតយ៉ាងតិច 6 ហ្វីតពីគ្នា។
  - ❑ ផ្លូវដើរច្បាស់លាស់ត្រូវបានកំណត់រវាងកន្លែងចតយានយន្ត ក៏ដូចជាចំណុចទៅដល់ផ្សេងទៀត និងទីកន្លែងនៅលើទីធ្លាដែលសេវាសាសនា ឬពិធីបុណ្យប្រឲ្យធម៌កំពុងប្រព្រឹត្តទៅដើម្បីកាត់បន្ថយហ្វូងមនុស្ស អនុញ្ញាតឲ្យមានការត្រួតពិនិត្យចំនួនមនុស្ស និងទុកពេលសម្រាប់ការត្រួតពិនិត្យរោគសញ្ញានៅពេលដែលបុគ្គលិក និងភ្ញៀវចូលមក។
  - ❑ បុគ្គលិកម្នាក់ (ឬច្រើននាក់បើសិនជាមានផ្លូវដើរច្រើនជាងមួយ) ដែលពាក់ក្រណាត់បាំងមុខ ត្រូវបានដាក់ឲ្យប្រចាំការនៅចំណុចចាប់ផ្តើមនៃផ្លូវដើរ ប៉ុន្តែមានគំលាតយ៉ាងតិច 6 ហ្វីតពីមនុស្សដែលមកដល់ឬចាកចេញ ដើម្បីត្រួតពិនិត្យការប្រើប្រាស់របាំងមុខ និងតាមដានចំនួនមនុស្ស។
  - ❑ ព្រឹត្តិការណ៍សាសនា និងពិធីបុណ្យប្រឲ្យធម៌ដែលបានអនុញ្ញាត ត្រូវបានរៀបចំដើម្បីទុកឲ្យមានចន្លោះ 6 ហ្វីតរវាងមនុស្ស 2 នាក់
    - ▪ ករណីលើកលែងតែមួយគត់គឺ មនុស្សទាំងពីរនាក់គឺជាប្តីប្រពន្ធដែលកំពុងរៀបអាពាហ៍ពិពាហ៍ ឬសមាជិកនៃគ្រួសារតែមួយ ដែលអាចចូលរួមក្នុងព្រឹត្តិការណ៍ណាមួយជាមួយគ្នា និងអង្គុយជាមួយគ្នាជាក្រុម បើសិនជាត្រូវបានអនុញ្ញាតដោយសាសនារបស់ពួកគេ។
  - ❑ បើសិនជាអ្នកចូលរួមនៅព្រឹត្តិការណ៍ ត្រូវតែតម្រង់ជួររង់ចាំមុននឹងមានកន្លែងអង្គុយ ឬនៅចំណុចផ្សេងទៀតណាមួយក្នុងអំឡុងពេលដែលពួកគេមកដល់ទីកន្លែង ការសម្គាល់ផ្សេងទៀតត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីគំលាត 6 ហ្វីតដែលចាំបាច់រវាងបុគ្គលម្នាក់ៗ។
  - ❑ សេវាកម្ម និងការប្រារព្ធពិធីត្រូវបានបំព្រួញឲ្យខ្លី ដើម្បីដាក់កម្រិតលើពេលវេលាដែលចំណាយនៅ

ទីកន្លែងនោះ។
  - ❑ ទីកន្លែងខាងក្រៅអគារត្រូវបានរៀបចំដើម្បីអនុញ្ញាតឲ្យមានការរក្សាគំលាតរាងកាយ។ បើសិនជាកៅអី បង់អង្គុយ ឬទីធ្លាឈរត្រូវបានប្រើ ការរៀបចំនិងការគូសសម្គាល់ត្រូវបានប្រើដើម្បីអនុញ្ញាតឲ្យមានគំលាត 6 ហ្វីតរវាងបុគ្គលម្នាក់ៗ ឬក្រុមគ្រួសារនីមួយៗ ក៏ដូចជាក្រុមគ្រួសារ ឬបុគ្គលផ្សេងៗទៀត។
  - ❑ បើអាចធ្វើបាន ផ្លូវរបៀងនៅក្នុងទីកន្លែងដែលប្រើសម្រាប់ព្រឹត្តិការណ៍ខាងក្រៅអគារ ត្រូវបានកំណត់ជាផ្លូវតែមួយទិសដើម្បីគាំទ្រការរក្សាគំលាតរាងកាយ។
  - ❑ ផ្លូវដើរ (podium) វេទិកា និងទីកន្លែងវាគ្មិនផ្សេងទៀត ត្រូវបានរៀបចំឡើងវិញដើម្បីអនុញ្ញាតឲ្យមានគំលាតយ៉ាងតិច 6 ហ្វីតរវាងវាគ្មិន ឬអ្នកចូលរួម។
  - ❑ បុគ្គលិកត្រូវបានណែនាំឲ្យរក្សាគំលាតយ៉ាងតិច 6 ហ្វីតពីគ្នានៅគ្រប់កន្លែងទាំងអស់នៃទីកន្លែងគោរពបូជា។
  - ❑ ការចូលប្រើបែបនិម្មិត ត្រូវបានផ្តល់ជូនសម្រាប់ភ្ញៀវដែលចង់ចូលរួមក្នុងសេវាកម្ម ឬព្រឹត្តិការណ៍ ប៉ុន្តែមានហានិភ័យ (risk) ខ្ពស់បើសិនជាប៉ះពាល់ជាមួយជំងឺ COVID-19។
- ❑ ការរៀបចំត្រូវបានធ្វើឡើងដើម្បីធ្វើឲ្យបន្ទប់ទឹកអាចប្រើប្រាស់បានប្រកបដោយសុវត្ថិភាពសម្រាប់អ្នកចូលរួមក្នុងព្រឹត្តិការណ៍នៅខាងក្រៅអគារ។ ទីកន្លែងអាចនឹងជ្រើសរើសផ្តល់បង្គន់ចល័តនៅខាងក្រៅ និងទីកន្លែងលាងដៃ និង/ឬបើកឲ្យប្រើបន្ទប់ទឹកក្នុងអគារ។ បើសិនជាទីកន្លែងក្នុងអគារត្រូវបានបើកឲ្យប្រើ គេត្រូវប្រកាន់ខ្ជាប់នូវការប្រុងប្រយ័ត្នដូចខាងក្រោម៖
  - ❑ ផ្លូវដែលបានកំណត់ត្រូវបានសម្គាល់ពីទីកន្លែងខាងក្រៅអគារដែលបានប្រើសម្រាប់ព្រឹត្តិការណ៍ចូលទៅកាន់ទីតាំងបន្ទប់ទឹកនៅខាងក្នុងអគារ។
  - ❑ បង់ស្ទិក ឬការសម្គាល់ផ្សេងទៀតត្រូវបានប្រើដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ បើសិនជាអ្នកចូលរួមត្រូវតែតម្រង់ជួរដើម្បីប្រើបន្ទប់ទឹក។
  - ❑ អ្នកចូលរួមត្រូវបានលើកទឹកចិត្តឲ្យប្រើបន្ទប់ទឹកតាមការចាំបាច់ក្នុងអំឡុងសេវាកម្ម ឬព្រឹត្តិការណ៍ ដើម្បីចៀសវាងការកកស្ទះនៅចុងបញ្ចប់។
  - ❑ សម្ភារៈក្នុងបន្ទប់ទឹកគឺស្ថិតក្នុងសភាពដំណើរការល្អជម្មតា និងមានផ្ទុកទៅដោយសាប៊ូ និងកន្សែងសម្រាប់ប្រើមួយដងគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យមានការលាងដៃដែលបានតម្រូវ។
  - ❑ សម្ភារៈក្នុងបន្ទប់ទឹកត្រូវបានរៀបចំដើម្បីអនុញ្ញាតឲ្យមានការរក្សាគំលាតរាងកាយនៅខាងក្រៅកូនបន្ទប់មានជញ្ជាំងបិទជិត។
  - ❑ បុគ្គលិកម្នាក់ (ឬច្រើននាក់បើសិនជាមានបន្ទប់ទឹកក្នុងអគារច្រើនជាងមួយ) ដែលពាក់ក្រណាត់បាំងមុខ ត្រូវបានដាក់ឲ្យប្រចាំការនៅច្រកចូលបន្ទប់ទឹក ប៉ុន្តែមានគំលាតយ៉ាងតិច 6 ហ្វីតពីមនុស្សដែលមកដល់ឬចាកចេញ ដើម្បីត្រួតពិនិត្យការប្រើប្រាស់របាំងមុខ និងតាមដានចំនួនមនុស្ស។
- ❑ បុគ្គលិកត្រូវបានណែនាំឲ្យរក្សាគំលាតយ៉ាងតិច 6 ហ្វីតពីគ្នានៅគ្រប់កន្លែងទាំងអស់នៃទីកន្លែង ដោយរាប់បញ្ចូលទាំងកន្លែងធ្វើការក្នុងអគារ។
- ❑ បើអាចអនុវត្តបាន ចំណុះជណ្តើរយន្តត្រូវបានដាក់កម្រិតត្រឹម 4 នាក់ ឬតិចជាងនេះនៅក្នុងពេលម្តងសម្រាប់ជណ្តើរយន្តទាំងឡាយដែលមិនអនុញ្ញាតឲ្យមានគំលាតរាងកាយ 6 ហ្វីតរវាងអ្នកជិះ។ អ្នកជិះទាំងអស់ត្រូវបានតម្រូវឲ្យពាក់ក្រណាត់បាំងមុខ។ ពិចារណាពីទំហំជណ្តើរយន្ត ចំនួនជាន់របស់អគារ និងចំនួនបុគ្គលិកប្រចាំថ្ងៃ ដើម្បីបង្កើតគោលការណ៍ណែនាំអំពីការរក្សាគំលាតរាងកាយដែលសមស្របសម្រាប់អ្នកជិះជណ្តើរយន្ត។
- ❑ បើអាចអនុវត្តបាន ជណ្តើរខាងក្នុងត្រូវបានបើកសម្រាប់ចរាចរណ៍ "ឡើង" ឬ "ចុះ" ដោយមានការសម្អាតជណ្តើរខាងក្នុងច្រើនជាងមុន។
- ❑ ស្ថានីយការងារនៅក្នុងការិយាល័យ ឬទីកន្លែងផ្សេងទៀត ត្រូវបានបំបែកពីគ្នាយ៉ាងតិច 6 ហ្វីត ហើយទីកន្លែងទូទៅត្រូវបានកំណត់ឲ្យដាក់កម្រិតលើការប្រមូលផ្តុំរបស់បុគ្គលិក ដើម្បីធានាបាននូវការរក្សាគំលាតពិតយ៉ាងតិច 6 ហ្វីត។
- ❑ ចំនួនបុគ្គលិកនៅក្នុងបន្ទប់ទឹក បន្ទប់សម្រាក និងទីកន្លែងទូទៅផ្សេងទៀតត្រូវបានដាក់កម្រិតដើម្បីអនុញ្ញាតឲ្យមានការរក្សាគំលាតរាងកាយ។

## C. វិធានការណ៍ដើម្បីគ្រប់គ្រងការឆ្លងជំងឺ

- ❑ ប្រព័ន្ធ HVAC គឺស្ថិតក្នុងសភាពដំណើរការល្អ ដល់កម្រិតអតិបរមា ដែលអាចធ្វើឲ្យខ្យល់ចេញចូលត្រូវបានបង្កើនឡើង តាមរយៈការបើកទ្វារ និងបង្អួចក្នុងអំឡុងពេលប្រមូលផ្តុំ។
- ❑ ពិចារណាដំឡើងម៉ាស៊ីនសម្អាតខ្យល់មានប្រសិទ្ធភាពខ្ពស់ចល័ត ធ្វើឲ្យប្រសើរឡើងនូវតម្រង

ខ្យល់របស់អគារឲ្យមានប្រសិទ្ធភាពខ្ពស់បំផុតតាមដែលអាចធ្វើបាន និងធ្វើការកែប្រែ ផ្សេងទៀត ដើម្បីបង្កើនបរិមាណខ្យល់ខាងក្រៅ និងខ្យល់ចេញចូលនៅក្នុងទីកន្លែងធ្វើការទាំង អស់។

- ❑ ឧបករណ៍ដែលមិនប្រើដៃ ត្រូវបានដំឡើងនៅគ្រប់ពេលដែលអាចធ្វើបាន (ដោយរាប់បញ្ចូលទាំងបន្ទប់ទឹក) ដើម្បីកាត់បន្ថយហានិភ័យ (risk) នៃការចម្លងមេរោគ។
- ❑ ការត្រួតពិនិត្យរោគសញ្ញាត្រូវបានធ្វើឡើងមុនពេលភ្ញៀវរួមទាំងសមាជិកជួបជុំមកដល់សម្រាប់សេវាកម្ម ឬព្រឹត្តិការណ៍សាសនាអាចនឹងចូលក្នុងទីកន្លែង។ ការត្រួតពិនិត្យ ត្រូវតែរាប់បញ្ចូលការពិនិត្យទាក់ទងនឹងការក្អក ដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងអការគ្រុនក្តៅឬគ្រុនរងា។ ការត្រួតពិនិត្យទាំងនេះអាចធ្វើបានដោយផ្ទាល់ ឬតាមរយៈវិធីផ្សេងដូចជាការពិនិត្យរោគសញ្ញាតាមអនឡាញ ឬតាមរយៈស្លាកសញ្ញាដែលបានបិទនៅច្រកចូលទីកន្លែងដោយថ្លែងថាភ្ញៀវដែលមានរោគសញ្ញាទាំងនេះមិនគួរចូលក្នុងទីកន្លែងឡើយ។
- ❑ ភ្ញៀវដែលមកដល់ទីកន្លែងត្រូវបានរំលឹកឲ្យពាក់របាំងមុខនៅគ្រប់ពេលវេលា (លើកលែងតែពេលបរិភោគ ឬផឹក បើសិនជាអាចធ្វើបាន) ខណៈពេលនៅក្នុងទីកន្លែង ឬនៅលើទីធ្លានៃទីកន្លែង។ នេះអនុវត្តទៅលើមនុស្សធំទាំងអស់ និងកុមារដែលមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ។ មានតែបុគ្គលដែលត្រូវបានណែនាំមិនឲ្យពាក់របាំងមុខដោយអ្នកផ្តល់សេវាវេជ្ជសាស្រ្តប៉ុណ្ណោះទើបត្រូវបានលើកលែងពីការពាក់នេះ។ ដើម្បីគាំទ្រសុវត្ថិភាពបុគ្គលិករបស់អ្នក និងភ្ញៀវផ្សេងទៀត គួរផ្តល់របាំងមុខឲ្យភ្ញៀវដែលមកដល់ដោយគ្មានវា។
- ❑ ស្លាកសញ្ញានៅទីតាំងដែលអាចមើលឃើញ ត្រូវបានប្រើដើម្បីរំលឹកដល់ភ្ញៀវថា របាំងមុខគឺចាំបាច់ក្នុងអំឡុងសេវាកម្ម និងការប្រារព្ធពិធីលើកលែងតែកុមារអាយុក្រោម 2 ឆ្នាំ ឬជនផ្សេងទៀតដែលពិបាកដកដង្ហើម ឬល័ក្ខខ័ណ្ឌមានហានិភ័យ (risk) ផ្សេងទៀត។
- ❑ ស្លាកសញ្ញានៅទីតាំងដែលអាចមើលឃើញ ហាមឃាត់ភ្ញៀវមិនឲ្យធ្វើការចាប់ដៃ ឱប ឬការស្វាគមន៍ស្រដៀងគ្នាដែលមានហានិភ័យ (risk) នៃការចម្លងមេរោគឡើយ។
- ❑ បើសិនជាសៀវភៅអធិដ្ឋាន ព្រំ ឬវត្ថុប៉ះពាល់ដោយផ្ទាល់ផ្សេងទៀត ត្រូវបានប្រើនៅក្នុងសេវាកម្ម ឬពិធីបុណ្យ បុគ្គលត្រូវបានណែនាំឲ្យយកវត្ថុរបស់ខ្លួន ឬវត្ថុដែលប្រើហើយអាចបោះចោលបានត្រូវបានផ្តល់ជូនសម្រាប់អ្នកចូលរួម។
- ❑ មីក្រូហ្វូន ជើងបញ្ឈរ ជើងបញ្ឈរតន្ត្រី ឧបករណ៍ និងវត្ថុផ្សេងទៀតនៅលើវេទិកា និងផូឌៀម(podiums) ត្រូវបានសម្លាប់មេរោគរវាងការប្រើប្រាស់ម្តងៗ។
- ❑ ទីកន្លែងបានបញ្ឈប់ការបញ្ជូនបន្តនូវថាសតង្វាយ និងវត្ថុស្រដៀងគ្នា។ ប្រព័ន្ធឌីជីថល ឬប្រអប់ ប្រមូលដោយមិនប៉ះ ឬឧបករណ៍ផ្សេងៗទៀតត្រូវបានប្រើសម្រាប់ការប្រមូលការចូលវិភាគទាន។
- ❑ នាយកដ្ឋានសុខភាពសាធារណៈរដ្ឋ California ណែនាំថា "សកម្មភាពដូចជាការច្រៀង និងការសូត្រធម៌ គឺផ្ទុយពីការកាត់បន្ថយហានិភ័យ (risk) ដែលសម្រេចបានតាមរយៈការរក្សាគំលាតរវាងកាយប្រាំមួយហ្វីត" ដោយសារការកើនឡើងនៃភាពអាចឆ្លងពីតំណក់ទឹកតូចៗដែលមានផ្ទុកមេរោគនៅពេលសាយភាយ។ សកម្មភាពទាំងអស់អាចនឹងត្រូវបានរាប់បញ្ចូលនៅក្នុងព្រឹត្តិការណ៍ខាងក្រៅអគារដោយមានគំលាតរវាងកាយកាន់តែឆ្ងាយ ឬតាមរយៈវិធីផ្សេង (ដូចជាការស្ទ្រីម តាមអ៊ីនធឺណិត) ដែលធ្វើឲ្យប្រាកដថាសមាជិកចូលរួមធ្វើសកម្មភាពទាំងនេះដាច់ដោយឡែកពីគ្នានៅតាមផ្ទះរបស់ខ្លួន។ សូមពិនិត្យមើលការណែនាំឧស្សាហកម្មរដ្ឋសម្រាប់ទីកន្លែងគោរពបូជា និងអ្នក ផ្តល់សេវាកម្មសាសនា និងពិធីបុណ្យវប្បធម៌ដែលបានធ្វើបច្ចុប្បន្នភាព នៅទីនេះ។
- ❑ ការចាប់ម្ហូបអាហារ និងភេសជ្ជៈដោយខ្លួនឯង មិនត្រូវបានផ្តល់ជូនឡើយ។
- ❑ បើសិនជាសេវាកម្មជាច្រើនត្រូវបានធ្វើឡើងជាប្រចាំថ្ងៃ គម្របកន្លែងអង្គុយដែលប្រើហើយអាចបោះចោលបាន ត្រូវបានផ្តល់ជូន។ គម្របដែលប្រើហើយអាចបោះចោលបាន ឬដែលអាចបោកគក់បាន ត្រូវបានផ្តល់ជូនសម្រាប់ខ្នើយដែលប្រើជាកន្លែងអង្គុយនៅលើកម្រាលឥដ្ឋ។ គម្របដែលអាចបោកគក់បាន ត្រូវបានផ្លាស់ប្តូរបន្ទាប់ពីប្រើប្រាស់ម្តងៗ។
- ❑ សំលៀកបំពាក់ និងក្រណាត់សាសនា ត្រូវបានបោកគក់ បន្ទាប់ពីសេវាកម្មឬព្រឹត្តិការណ៍នីមួយៗនៅក្នុងការកំណត់សីតុណ្ហភាពទឹកខ្ពស់បំផុតដែលអាចធ្វើបាន។
- ❑ ទីកន្លែងការងារ និងអគារទាំងមូលត្រូវបានសម្អាតយ៉ាងតិចជាប្រចាំថ្ងៃនៅពេលប្រើប្រាស់ ដោយបន្ទប់ទឹក និងតំបន់/វត្ថុដែលបានប៉ះញឹកញាប់ ត្រូវបានសម្អាតញឹកញាប់ជាង។
- ❑ ទីកន្លែងត្រូវបានបិទដល់សាធារណជននៅចន្លោះព្រឹត្តិការណ៍ដែលបានកំណត់កាលវិភាគ ដើម្បីចៀសវាងការចម្លងមេរោគ។
- ❑ បុគ្គលិកដែលទទួលខុសត្រូវលើការសម្អាតចន្លោះព្រឹត្តិការណ៍/ឬនៅថ្ងៃឈប់សម្រាក ទទួលប្រាក់ឈ្នួលសម្រាប់ពេលវេលាដែលបានចំណាយលើភារកិច្ចទាំងនេះ បើសិនជាវាមិនមែនជាផ្នែកនៃកិច្ចការជាប្រចាំរបស់ខ្លួន។
- ❑ ស្លាកសញ្ញាបន្ទប់ទឹក រំលឹកភ្ញៀវឲ្យលាងដៃឲ្យបានញឹកញាប់រយៈពេល 20 វិនាទី។
- ❑ សម្ភារៈក្នុងបង្គន់ ត្រូវបានរក្សាឲ្យដំណើរការធម្មតា និងមានផ្ទុកសាប៊ូ ក្រដាសជូត និងទឹកអនាម័យលាងដៃបន្ថែម និងត្រូវបានធ្វើអនាម័យជាប្រចាំដោយប្រើសារធាតុសម្លាប់មេរោគអនុម័តដោយ EPA ដោយ

អនុវត្តតាមការណែនាំរបស់ក្រុមហ៊ុនផលិតតាមកាលវិភាគដូចខាងក្រោម៖ ____________________________________________

- ❑ ទឹកអនាម័យលាងដៃ ក្រដាសជូតមាត់ និងធុងសម្រាមគឺមានសម្រាប់សាធារណជននៅ ឬជិតច្រកចូលទីកន្លែង។
- ❑ ស្រេចចិត្ត - ពិពណ៌នាពីវិធានការណ៍ផ្សេងៗទៀតដើម្បីលើកកម្ពស់ការគ្រប់គ្រងការឆ្លងជំងឺ
____________________________________________

## D. វិធានការណ៍ដែលទំនាក់ទំនងជាមួយសាធារណជន

- ❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូលសាធារណៈទាំងអស់មកក្នុងទីកន្លែង។
- ❑ ច្រកអនឡាញនៃការប្រមូលផ្តុំ (គេហទំព័រ បណ្តាញសង្គម ។ល។) ផ្តល់ព័ត៌មានច្បាស់លាស់អំពីកាលវិភាគ ការកំណត់ចំនួនមនុស្ស ការកំណត់លើការចតយានយន្ត ការតម្រូវឲ្យប្រើរបាំងមុខ និងជម្រើសសម្រាប់ការចូលរួមបែបនិម្មិត។

## E. វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

- ❑ សេវាកម្មដែលចាំបាច់ខ្លាំងសម្រាប់សមាជិកចូលរួម ត្រូវបានផ្តល់អាទិភាព។
- ❑ សេវាកម្មដែលអាចត្រូវបានផ្តល់ពីចម្ងាយ ត្រូវបានប្តូរទៅអនឡាញ
- ❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវការទទួលបានសេវាកម្ម និងការប្រារព្ធពិធីសម្រាប់សមាជិកចូលរួមដែលមានការលំបាកក្នុងការផ្លាស់ទី និង/ឬដែលមានហានិភ័យ (risk) ខ្ពស់នៅទីសាធារណៈ។

**វិធានការណ៍បន្ថែមទាំងឡាយដែលខុសពីខាងលើ គួរត្រូវបានរាយ នៅលើទំព័រដាច់ដោយឡែក ដែលទីកន្លែងគួរភ្ជាប់ជាមួយឯកសារនេះ។**

**អ្នកអាចទាក់ទងបុគ្គលខាងក្រោមជាមួយសំណួរ ឬមតិអំពីពិធីការនេះ៖**

**ឈ្មោះទំនាក់ទំនងនៅទីកន្លែង៖** ____________________

**លេខទូរសព្ទ៖** ____________________

**កាលបរិច្ឆេទកែសម្រួលចុងក្រោយ៖** ____________________